World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨៦

របាយការណ៍គិតត្រឹមថ្ងៃទី ២ ខែឧសភា ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី១៨ មេសា ដល់ថ្ងៃ ១ ឧសភា ឆ្នាំ២០២២)*

- ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី បញ្ជាក់ដោយ PCR សរុបចំនួន ១៧៨ និងគ្មានករណីស្លាប់ថ្មីទេ ដោយសារជំងឺកូវីដ-១៩ចំនួន ១ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោមករណីនោះ  ១៧១ករណី ឬ ៩៦ភាគរយជាករណីឆ្លងក្នុងសហគមន៍ ហើយ ៧ករណី ឬ ៤ភាគរយជាករណីនាំ ចូលពីក្រៅប្រទេស។ ចំនួនករណីឆ្លងថ្មីបានធ្លាក់ចុះចំនួន ៣៩ភាគរយ បើធៀបទៅនឹងរយៈពេល១៤ថ្ងៃកន្លងទៅ។

- គិតត្រឹមថ្ងៃទី ១ ខែឧសភា ឆ្នាំ២០២២ ករណីសរុបទាំងអស់ចំនួន ១៣៦.២៥៤  ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០៥៦ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០មក។ ក្នុងចំណោមនោះ ១៣៣.១១៦ករណីបានជាសះស្បើយ។

- គិតត្រឹមថ្ងៃទី ១ ខែឧសភា ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៦១៦.៣០០ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)  នៅកម្ពុជា។ រយៈពេល១៤ថ្ងៃកន្លងទៅ បានធ្វើតេស្តចំនួន ៥.៣១៥ រកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ។

- មិនមានភ័ស្តុតាងនៃការកើនឡើងនៃចង្កោមករណី និងការសម្រាកព្យាបាលនៅមន្ទីរពេទ្យទេ បន្ទាប់ពីការធ្វើដំណើរក្នុងស្រុក និងការជួបជុំគ្នាយ៉ាងច្រើនក្នុងអំឡុងពេលពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។ សមត្ថភាពប្រព័ន្ធសុខាភិបាលនៅតែមានស្ថេរភាពជាមួយនឹងការថយចុះនៃទំនោរនៃការប្រើប្រាស់សេវាសុខាភិបាលសម្រាប់ជំងឺកូវីដ១៩។
- ការពាក់ម៉ាសជាកាតព្វកិច្ចនៅទីសាធារណៈ  នៅទីតាំងខាងក្រៅ និងទីតាំងបើកចំហរ ក្នុងប្រទេសកម្ពុជាត្រូវបានដកចេញនៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២២។ ប្រជាជនអាចសម្រេចចិត្តដោយខ្លួនឯង ប៉ុន្តែនៅតែត្រូវបានលើកទឹកចិត្តឱ្យពាក់ម៉ាស់នៅកន្លែងសាធារណៈដែលមានមនុស្សកុះករច្រើន។ ការពាក់ម៉ាសនៅតែជាកាតព្វកិច្ចសម្រាប់កន្លែងបិទជិត និងទីតាំងនៅខាងក្នុង។
  ការពង្រឹងប្រព័ន្ធតាមពហុប្រភព ដើម្បីធានាការរកឃើញទាន់ពេលនៃព្រឹត្តិការណ៍ ការកែសម្រួលនូវ វិធានការសុខភាពសុខាភិបាល និងសង្គម (PHSM) ការពង្រឹងការផ្តល់សេវាសុខភាព និងការពន្លឿនការចាក់វ៉ាក់សាំង ដែលផ្តោតលើក្រុមងាយរងគ្រោះនៅតែជាតំបន់អាទិភាពដើម្បីគ្រប់គ្រងកូវីដ-១៩ និងបញ្ហាផ្សេងៗនាពេលអនាគតប្រកបដោយនិរន្តរភាព។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- **ការតាមដាន**

  - ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព ក្រោមការផ្តល់បច្ចេកទេសពីអង្គការសុខភាពពិភពលោកកំពុងរៀបចំការតាមដានការចូលរួមរបស់សហគមន៍ដើម្បីពង្រឹងការរកឃើញជំងឺកូវីដ១៩ឲ្យបានឆាប់ និងជំងឺឆ្លងអេពីដេមីកដទៃទៀត។

  - អង្គការសុខភាពពិភពលោកកំពុងពង្រឹងសម្ថភាពដល់មន្ត្រីសុខាភិបាលថ្នាក់ខេត្តតាមរយៈអនុវត្តលំហាត់សមយុទ្ធអំពីការអង្កេតចង្កោមករណីទៅលើទីតាំងហានិភ័យខ្ពស់ និងក្រុមងាយរងគ្រោះ



* គិតត្រឹមខែឧសភា ឆ្នាំ ២០២២ របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាលកម្ពុជា នឹងត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃច័ន្ទលើកទីពីរនៃខែនីមួយៗ។

**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- **មន្ទីរពិសោធន៍**
  - ការធ្វើតេស្តរកមេរោគកូវីដ-១៩ នៅរាជធានីភ្នំពេញ និងធ្វើ sequencing កំពុងត្រូវបានរៀបចំឡើងនៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH)។ មន្ទីរពិសោធន៍ខេត្តដែលបំពាក់ដោយ GeneXpert កំពុងបន្តការធ្វើតេស្ត PCR សម្រាប់សំណាក COVID-19 ដែលទទួលបាន

## វិធានការសុខាភិបាល និងសង្គម

- នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២២ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានសម្រេចលុបចោលកាតព្វកិច្ចការពាក់ម៉ាស់ជាចាំបាច់នៅទីសាធារណៈ និង នៅទីតាំងដែលមានខ្យល់ចេញចូលបានល្អ នៅទូទាំងប្រទេស។ ប្រជាជនអាចសម្រេចចិត្តថាតើត្រូវពាក់ម៉ាសឬមិនពាក់ម៉ាសនៅកន្លែងក្រៅ ប៉ុន្តែនៅតែត្រូវបានលើកទឹកចិត្តឱ្យពាក់ម៉ាស់នៅពេលនៅកន្លែងដែលមានមនុស្សកុះករច្រើន។ ការពាក់ម៉ាសនៅតែជាកាតព្វកិច្ចសម្រាប់ការទីតាំងនៅខាងក្នុង និងកន្លែងបិទជិត ដូចជាបន្ទប់ប្រជុំ និងរោងភាពយន្ត។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- អង្គការសុខភាពពិភពលោកកំពុងធ្វើការងារជាមួយមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពដើម្បីធ្វើបច្ចុប្បន្នភាព “ ការអនុវត្តការចូលរួមរបស់សហគមន៍ ដើម្បីពង្រឹងការតាមដានដោយមានការចូលរួមរបស់ហគមន៍ចំពោះជំងឺកូវីដ-១៩ ជំងឺផ្តាសាយ និងសម្ភារ:សម្រាប់ពង្រឹងសម្ថភាពទាក់ទងនឹងមេរោគផ្លូវដង្ហើមផ្សេងៗ និងការរៀបចំផែនការ ដែលនឹងអនុវត្តនៅក្នុងខេត្តចំនួន ៩ នៅពាក់កណ្តាល ខែឧសភា ឆ្នាំ ២០២២ នេះ។
- អង្គការសុខភាពពិភពលោកបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើម្បីរៀបចំផែនការ ផលិតវីដេអូអប់រំខ្លីៗចំនួន ៥ ជាមួយនឹងអ្នកជំនាញក្នុងស្រុក ដើម្បីផ្តល់សារអប់រំទាក់ទងនឹងបញ្ហាដែលកំពុងកើតឡើងថ្មីៗ និងការគ្រប់គ្រងដែលមាននិរន្តរភាពចំពោះជំងឺកូវីដ-១៩ និងការរៀបចំប្រុងប្រៀបខ្លួនសម្រាប់អនាគត។
- អង្គការសុខភាពពិភពលោកបានសម្របសម្រួលជាមួយដៃគូធ្វើការងារផ្នែកសុខាភិបាល និងរដ្ឋអំណាចមូលដ្ឋាន ស្ថាបន័រដ្ឋ និងវិស័យឯកជន ដើម្បីផ្សព្វផ្សាយពីគោលការណ៍ណែនាំជាក់លាក់ដល់ប្រជាពលរដ្ឋ អំពីសារសំខាន់នៃការចាក់វ៉ាក់សាំង និងដូសជំរុញ ជាពិសេស ដល់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ និងសហគមន៍ដែលមានហានិភ័យនៃការចម្លងជំងឺកូវីដ-១៩។
- ការិយាល័យអង្គការសុខភាពពិភពលោកប្រចាំតំបន់ បានអនុវត្តយុទ្ធនាការនិទានរឿង “ប្រជាពលរដ្ឋនៃតំបន់អាស៊ីប៉ាស៊ីហ្វិកខាងលិច: រឿងពាក់ពន្ធ័នឹងជំងឺកូវីដ-១៩” ដើម្បីជម្រុញ និងលើកទឹកចិត្តប្រជាពលរដ្ឋនៃបណ្តាប្រទេសនៅក្នុងតំបន់ ឲ្យរក្សានិងយកចិត្តទុកដាក់ចំពោះវិធានការការពារ និងទៅទទួលវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ និងដើម្បីជួយពួកគេឲ្យមានការយល់ដឹងអំពីវិធានការការពារមួយចំនួន នៅក្នុងស្ថានភាពដែលកើតឡើងផ្សេងៗគ្នា និងជំរុញឲ្យមានការបង្កើតវិធានការការពារនានា។ អង្គការសុខភាពពិភពលោកបានស្នើឲ្យមានការផ្ញើររឿងនិទានតាមរយ: ការបំពេញទម្រង់ចុះឈ្មោះអនឡាញ។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- វ៉ាក់សាំងកូវីដ-១៩ ប្រភេទអាស្ត្រាសេនេកា AZ (Vaxzevria) ចំនួន ១,០៥៦,០០០ ដូស ដែលជាអំណោយដ៏ថ្លៃថ្លាពីរដ្ឋាភិបាល និង ប្រជាជន នៃសាធារណ:រដ្ឋអ៊ីតាលី ជូនពរាជរដ្ឋាភិបាល និង ប្រជាជន នៃព្រះរាជាណាចក្រកម្ពុជាបានមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២។ មកដល់ថ្ងៃនេះប្រទេសកម្ពុជាបានទទួលវ៉ាក់សាំងកូវីដ-១៩ ទាំងអស់ចំនួន ៥០,៨៣៥,៨៦០ ដូស ។
- ក្រសួងសុខាភិបាលបានប្រកាសជូនដំណឹង នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ដល់គណ:កម្មាធិការ និងអាជ្ញាធរខេត្តទាំងអស់ ដើម្បីអប់រំប្រជាពលរដ្ឋគ្រប់វ័យ ដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន និង ដូសជុំរុញ សូមទៅចាក់អោយបានគ្រប់ៗគ្នា ។ ប្រជាជនកម្ពុជាទូទៅ គ្រប់គ្នាត្រូវតែទទួលបានចំនួន៣ដូសជាការចាំបាច់បំផុតដើម្បីអោយមានភាពស៊ាំនៅក្នុងសហគមន៍។ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ធ្វើឡើងក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរ និងក្រោយបុណ្យចូលឆ្នាំខ្មែរ ដោយចាក់ជូនប្រជាពលរដ្ឋដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន និង ដូសជុំរុញ តាមរយ:៖



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ❖ ការបង្កើនទីតាំងផ្តល់វ៉ាក់សាំងកូវីដ-១៩ ចល័ត នៅតាមវត្តអារាម រោងចក្រ សាលារៀន ទីសាធារណៈ និង កន្លែងកំសាន្ត ឬ តំបន់ទេសចរណ៍នានានៅទូទាំងប្រទេសកម្ពុជា។
- ❖ បន្តអនុវត្តការចុះចាក់វ៉ាក់សាំងកូវិដ-១៩ នៅតាមទីប្រជុំជន សហគមន៍ក្រីក្រ សហគមន៍ជនជាតិភាគតិច និង ភូមិ ឬ សហគមន៍ដែលមានហានិភ័យខ្ពស់។
- ❖ ជំរុញនិង កៀងគរអ្នកគាំទ្រនៅក្នុងមូលដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ និង ចុះឈ្មោះអ្នកដែលខកខានមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន និង ដូសជំរុញ អោយពួកគាត់មកចាក់អោយបានគ្រប់ៗគ្នា ព្រមបង្កើនការទំនាក់ទំនងជាមួយសាធារណជនសម្រាប់ការលើកកំពស់ ការយល់ដឹងរបស់ពួកគាត់អំពីផលប្រយោជន៍នៃការចាក់ វ៉ាក់សាំងកូវីដ-១៩ និង តម្រូវការនៃការចាក់សាំង ដោយធ្វើការផ្សព្វផ្សាយ និងតាមដានអោយបានជាប្រចាំ។
- ❖ បង្កើនក្រុមចាក់វ៉ាក់សាំងចល័តក្រៅពីក្រុមគ្រូពេទ្យក្រសួងសុខាភិបាល (ឧ. ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចវិបុលសេនាភក្តី សាយ ឈុំ និងគ្រូពេទ្យសហភាពសហព័ន្ធយុវជនកម្ពុជាជាដើម)។

- ▪ យុទ្ធសាស្រ្តចុះចាក់វ៉ាក់សាំងនៅតាមមូលដ្ឋានក៏បានរួមបញ្ចូលផងដែរនូវការអនុវត្តការចុះចាក់វ៉ាក់សាំងកូវីដ-១៩ ពីផ្ទះមួយទៅផ្ទះមួយ ការចាក់វ៉ាក់សាំងនៅក្រៅពីម៉ោងធ្វើការ ដើម្បីគ្របដណ្តប់លើប្រជាជនដែលងាយរងគ្រោះដូចជា ជនពិការ មនុស្សចាស់ជរា អ្នកមានជំងឺប្រចាំកាយ និង កម្មករ។
- ▪ អង្គការសុខភាពពិភពលោកគាំទ្រទាំងបច្ចេកទេស និង ថវិការដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដូចជា ៖

- ❖ ការគាំទ្រផ្នែកបច្ចេកទេសក្នុងការកំណត់អត្តសញ្ញាណអ្នកដែលខកខានមិនទាន់បានទទួលវ៉ាក់សាំងដូសមូលដ្ឋានគ្រប់ចំនួន(២ដូស) និង ដូសជំរុញ កសាងផែនការលំអិតនៅថ្នាក់ក្រោមជាតិ ការចុះអភិបាលទៅលើការអនុវត្តសកម្មភាពនៅកន្លែងដែលបានកំណត់ និងការចាក់វ៉ាក់សាំងចល័តនៅតំបន់គ្របដណ្តប់ទាប តំបន់ព្រំដែន សហគមន៍ពិបាកទៅដល់ ការវាយតម្លៃការគ្របដណ្តប់រហ័ស និងការណែនាំ ព្រមទាំងការផ្តល់អនុសាសន៍នៅនឹងកន្លែងចាក់វ៉ាក់សាំងជាដើម ដើម្បីអោយប្រជាជនដែលមានសិទ្ធិចាក់វ៉ាក់សាំងទាំងអស់បានទួលវ៉ាក់សាំងគ្រប់គ្នា។
- ❖ ឧបត្ថម្ភថវិកាដល់ខេត្តមួយចំនួន ដែលមាន ភូមិ ឬ សហគមន៍ដែលមានលំបាក និង មានកម្មករ ដើម្បីអោយក្រុមចាក់វ៉ាក់សាំង ចុះចាក់វ៉ាក់សាំង នៅភូមិ ឬ សហគមន៍ដែលមានលំបាក និងមានកម្មករទាំងនោះ។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- ▪ គោលការណ៍ណែនាំសម្រាប់អនុវត្តការធ្វើសមាហរណ៍កម្មសេវាព្យាបាលជំងឺកូវីដ-១៩ទៅក្នុងប្រព័ន្ធថៃទាំផ្នែកសុខាភិបាលតែ មួយដែលត្រូវបានគាំទ្របច្ចេកទេសដោយអង្គការសុខភាពពិភពលោក ត្រូវបានទទួលការយល់ព្រមដោយក្រសួងសុខាភិបាល និងត្រូវបានចេញជាផ្លូវការនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២។ រាល់មូលដ្ឋានសុខាភិបាលទាំងរដ្ឋ និងឯកជនទាំងអស់ត្រូវបានផ្តល់ដំបូន្មានឲ្យអនុវត្តនូវគោលការណ៍ណែនាំនេះឲ្យមានប្រសិទ្ធភាពនៅទូទាំងប្រទេស។ រសិទ្ធភាពនៅទូទាំងប្រទេស។ ចេញគោលការណ៍ណែនាំនេះ គណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដក្រោយពីការអាជ្ញាធររាជធានី-ខេត្តទាំងអចេញគោលការណ៍ណែនាំនេះ គណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដអនុវត្ត-១៩ បានផ្តល់ដំបូន្មានដល់អាជ្ញាធររាជធានី-ខេត្តទាំងអស់ ឲ្យចូលរួមអនុវត្តគោលការណ៍នេះឲ្យមានប្រសិទ្ធភាពផងដែរ។
- ▪ អ្នកជំងឺកូវីដ-១៩ទាំងអស់នៅមណ្ឌលព្យាបាលអូឡាំពិក ក្នុងទីក្រុងភ្នំពេញ ត្រូវបានផ្ទេរចេញទៅមន្ទីរពេទ្យហ្លួងម៉ែ ឬមណ្ឌលសុខភាពចាក់អង្រែក្រោម ដើម្បីអនុញ្ញាតឲ្យពហុកីឡាដ្ឋានជាតិអូឡាំពិកទុកសម្រាប់ជាមណ្ឌលហ្វឹកហ្វឺនផ្នែកកីឡាវិញ។

## វិធានការព្រំដែនអន្តរជាតិ

- ▪ នៅថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០២២ រាជរដ្ឋាភិបាលបានប្រកាសកាត់បន្ថយកាតព្វកិច្ចការធ្វើចត្តាឡីស័កពី ១៤ ថ្ងៃមកត្រឹម៧ ថ្ងៃសម្រាប់អ្នកធ្វើដំណើរដែលមិនបានចាក់វ៉ាក់សាំង។ អ្នកធ្វើដំណើរតាមយន្តហោះដែលមិនបានចាក់វ៉ាក់សាំងនឹងត្រូវតម្រូវឱ្យធ្វើតេស្តនៅថ្ងៃទី ៧ ខណៈ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ពេលដែលអ្នកធ្វើដំណើរឆ្លងកាត់ព្រំដែនគោកតម្រូវឱ្យធ្វើតេស្តនៅថ្ងៃទី ១ និងថ្ងៃទី ៧ ។ ការធ្វើតេស្ត និងការធ្វើចត្តាឡីស័កគឺមិនត្រូវបានទាមទារសម្រាប់អ្នកធ្វើដំណើរដែលបានចាក់វ៉ាក់សាំងពេញលេញចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២២។

ច្រកទ្វារព្រំដែនប៉ោយប៉ែត ព្រំដែនកម្ពុជា-ថៃ បើកដំណើរការឡើងវិញ ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២។

## អេពីដេមីសាស្ត្រ

**ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ ២០២១-២០២២***




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ។ការតម្រូវធ្វើតេស្តសម្រាប់អ្នកដំណើរដែលចូលមកកម្ពុជាត្រូវបានលុបចោលចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២២

**តារាងទី១. តារាងសង្ខេបអំពីសូចនាករកូវីដ-១៩**

| | | | | |
|---|---|---|---|---|
| បច្ចុប្បន្នភាព អេពីដេមីសាស្ត្រ អំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
| | ៥.៣១៥ | ១៧១ | ០ | ៧ |
| | ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | ២.៦១៦.៣០០ | ១៣៦.២៥៤ | ៣.០៥៦ | |
| | ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | ករណីសរុប | ករណីស្លាប់សរុប | |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

| ការផ្តល់សេវាសុខភាព អំពីកូវីដ-១៩ | 79<br>ចំនួនមន្ទីរពេទ្យ ដែលទទួលព្យាបាល អ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាល អ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែអ្នកជំងឺធ្ងន់ដែលមាននៅ មន្ទីរពេទ្យ និង មណ្ឌលព្យាបាល |
|---|---|---|---|

**តារាងទី២. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញ  វ័យ និងកុមារ)**

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | | យុវវ័យ និងកុមារ | | |
|---|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៣-៥ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ | អាយុចាប់១២ ឆ្នាំដល់ក្រោម ១៨ឆ្នាំ |
| | **(N=43,646)** | **(N=1,378,688)** | **(N=10,000,000)** | **(N=610,730)** | **(N=304,317)** | **(N=1,897,382)** | **(N=1,827,348)** |
| ចាប់ផ្តើម | 10 កុម្ភៈ 2021 | 10 កុម្ភៈ 2021 | 10 កុម្ភៈ2021 | 22 កុម្ភៈ 2022 | 1 វិច្ឆិកា 2021 | 17 កញ្ញា 2021 | 1 សីហា 2021 |
| **ដូសទី១** | 43,646 (100%) | 1,411,594 (102.4%) | 10,297,069 (103.0%) | 365,874 (59.9%) | 392,022 (128.8%) | 2,058,023 (108.5%) | 1,834,289 (100.4%) |
| **ដូសទី២** | 43,646 (100%) | 1,395,544 (101.2%) | 9,948,367 (99.5%) | 178,132 (29.2%) | 315,516 (103.7%) | 1,994,343 (105.1%) | 1,771,554 (96.9%) |
| **ដូសទី៣** | 43,646 (100%) | 917,419 (66.5%) | 6,247,197 (62.5%) | N/A | 18,736 (6.2%) | 1,027,685 (54.2%) | 1,310,624 (71.7%) |
| **ដូសទី៤** | 1,739,836 (17.4%) | | | N/A | N/A | N/A | 18,486 (1.0%) |

**តារាងទី៣. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំង កូវីដ-១៩**

| ប្រភេទវ៉ាក់សាំង កូវីដ-១៩ | **Sinovac** | Sinopharm | AstraZeneca (Covishield) | **Janssen** (Ad26.COV2-S) | **AstraZeneca** (Vaxzevria) | **Moderna** (Spikevax) | **Pfizer** BioNTech (Comirnary) | **សរុប** |
|---|---|---|---|---|---|---|---|---|
| ចំនួករណី | 101 | 79 | 29 | 4 | 1 | 3 | 0 | **217** |
| ចំនួនដូសសរុប បានចាក់ | 24,596,127 | 7,483,537 | 323,344 | 1,053,151 | 3,436,456 | 352,161 | 1,219,826 | **38,464,602** |
| អត្រានៃហេតុការណ៍ក្នុង ចំណោម ១០០.០០០ដូស | 0.41 | 1.06 | 8.97 | 0.38 | 0.03 | 0.85 | 0 | **0.56** |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## ឯកសារយោង និងតំណភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។